របាយការណ៍ឃ្លាំមើលលើកទី៩

# ស្ដីពី ស្ថានភាពព្រៃឡង់

រាជរដ្ឋាភិបាល បានហាមឃាត់ការល្បាតការពារព្រៃឈើ គឺជាការ
ពន្លឿនការកាប់បំផ្លាញព្រៃឈើ!



## សូមឱ្យបណ្ដាញសហគមន៍ព្រៃឡង់ អាចល្បាតព្រៃជាថ្មីឡើងវិញ!

តាងនាមឲ្យបណ្ដាញសហគមន៍ព្រៃឡង់(PLCN)៖ ARGYRIOU D., BORI P. , THEILADE I.[1]
[1]សាកលវិទ្យាល័យ កូប៉ិនហាហ្គិន (Copenhagen)

# សេចក្តីផ្តើម

## តារាងបាត់បង់ព្រៃឈើប្រចាំឆ្នាំ ២០០០-២០១៩

ហិកតា (ha)




**រូបភាពទី១:** ការបាត់បង់គម្របព្រៃឈើ (ទិន្នន័យគម្របព្រៃឈើសាកល)

ព្រៃការពារដែនជម្រកសត្វព្រៃ ព្រៃឡង់ ស្ថិតនៅភាគកណ្តាលនៃប្រទេសកម្ពុជា គ្របដណ្តប់លើផ្ទៃដីព្រៃជាងកន្លះលានហិកតា ជាជម្រកដ៏មហិមានៃរុក្ខជាតិ និងពពួកសត្វជាច្រើនប្រភេទ។ ព្រៃឈើក្នុងតំបន់ព្រៃឡង់ គឺជាព្រៃមួយប្រភេទដែលនៅសេសសល់លើតំបន់វាលទំនាប ជាព្រៃស្រោងនៅអាស៊ីអាគ្នេយ៍។ ជាតំបន់ជីវចម្រុះមានតួនាទីសំខាន់ទៅលើជីវភាពសហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិចកួយ ជាអ្នកទទួលផលតាមការប្រើប្រាស់ប្រកបដោយនិរន្តរភាព ទាំងការដកហូតឈើ និងអនុផលព្រៃឈើ។

ទោះជាយ៉ាងនេះក្តី ជាច្រើនទសវត្សរ៍មកហើយ តុល្យភាពរវាងបរិស្ថានធម្មជាតិ ជាមួយនឹងសហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិច មានភាពមិនទៀងទាត់ឡើយ ដែលវាបានរំខានដោយការអភិវឌ្ឍធំៗ និងសកម្មភាពកាប់ឈើខុសច្បាប់ជាបន្តបន្ទាប់។ ចន្លោះរវាងឆ្នាំ២០០០ រហូតដល់២០១៩ មានផ្ទៃដីព្រៃប្រមាណជា ១០៣,០០០ហិតា ឬស្មើរនឹង១១% នៃគម្របព្រៃឈើ ត្រូវបានបាត់បង់ដោយការចូលទៅប្រតិបត្តិការកាប់ឈើពីសំណាក់ក្រុមហ៊ុនសម្បទានដែលនៅតាមតំបន់ជាប់ជាមួយនឹងព្រៃឡង់ ,។ គ្រាន់តែនៅក្នុងឆ្នាំ២០១៩ ព្រៃឡង់បានបាត់អស់ ៧,៥៧០ហិតារួចទៅហើយ គឺបាត់បង់ព្រៃឈើស្មើនឹងទំហំតារាងបាល់ទាត់អូឡាំពិកមួយ ក្នុងរយៈពេលមួយម៉ោង។ វាគឺជាសញ្ញាដែលត្រូវប្រកាសអាសន្ន ដើម្បីចូលរួមជាបន្ទាន់ក្នុងការបញ្ឈប់ការបាត់បង់នេះ ។ ការបាត់បង់ព្រៃឈើនៅក្នុងឆ្នាំ២០១៩ ត្រូវបានជំនួសដោយការបំផ្លាញព្រៃឈើដ៏មហិមានៅក្នុងឆ្នាំ២០១៦ (មើលរូបភាព១)។ ជាការប៉ាន់ប្រមាណជាបន្តបន្ទាប់លើការបំភាយឧស្ម័នកាបូនិក ផ្អែកលើទិន្នន័យគម្របព្រៃឈើ បានបង្ហាញនូវកំណើន៧៣% ក្នុងឆ្នាំ២០១៩ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៨ (មើលតារាងទី១)។

បណ្តាញសហគមន៍ព្រៃឡង់ (PLCN) គឺជាបណ្តុំសហគហគមន៍ដែលធ្វើការងាររួមគ្នា ដើម្បីការពារព្រៃឡង់ ចាប់តាំងពីឆ្នាំ២០០០ មកម្លេះ។ បណ្តាញសហគមន៍ព្រៃឡង់បានបញ្ចេះបញ្ចូល ដើម្បីការពារការកាប់ឈើខុសច្បាប់ ការអភិវឌ្ឍ និងការចូលកាន់កាប់ដីនៃបុព្វបុរស ការរុករករ៉ែ ជីវកម្មកសិកម្ម និងការកាត់ឈើ តាមរយៈសកម្មភាពអហិង្សាសកម្ម និងសកម្មភាពនៃការពិភាក្សាដោយសន្តិភាព។ បណ្តាញសហគមន៍ព្រៃឡង់បានសហការជាមួយអ្នកពាក់ពន្ធ័យ៉ាងទូលាយ ដើម្បីការពារព្រៃ និងជីវភាពរបស់ប្រជាពលរដ្ឋ ប្រហែល២០០,០០០នាក់ ជាអ្នកដែលអាស្រ័យអនុផលព្រៃឈើ។

ក្នុងនាមជាបណ្តុំសហគមន៍មូលដ្ឋាន បណ្តាញសហគមន៍ព្រៃឡង់ មានការរួមបញ្ចូលនូវការប្រើប្រាស់កម្មវិធីអេប ក្នុងការល្បាតព្រៃឈើ។ ពួកគេធ្វើការប្រមូលនូវទិន្នន័យព្រៃឈើ ជីវចម្រុះ សកម្មភាពកាប់ឈើខុសច្បាប់ បម្រែបម្រួលអាកាសធាតុ និងការធ្វើអន្តរកម្មជាមួយអាជ្ញាធរ រួមទាំងការគម្រាមកំហែងមកលើសមាជិករបស់ពួកគេផងដែរ។ នៅក្នុងកំឡុងពេលល្បាត បណ្តាញសហគមន៍ព្រៃឡង់ធ្វើការរឹបអូសរណាយន្តពីអ្នកកាប់ឈើខុសច្បាប់ និងការធ្វើកិច្ចសន្យាផ្តិតមេដៃឲ្យបញ្ឈប់នូវសកម្មភាពខុសច្បាប់។ ការរឹបអូសបាននូវសម្ភារៈទាំងឡាយ គឺប្រគល់ឱ្យទៅស្នាក់ការមន្រ្តីឧទ្យានុរក្សរបស់ក្រសួងបរិស្ថាន។ ទោះជាយ៉ាងនេះក្តី បណ្តាញសហគមន៍ព្រៃឡង់ បានកត់សម្គាល់ឃើញថា រណាយន្តដែលប្រគល់ជូន មន្រ្តីឧទ្យានុរក្សទាំងនោះ តែងតែធ្លាក់ទៅលើដៃក្រុមអ្នកកាប់ឈើវិញ។

បណ្តាញសហគមន៍ព្រៃឡង់ បានទទួលនូវពានរង្វាន់អន្តរជាតិជាច្រើន ចំពោះកិច្ចខិតខំប្រឹងប្រែងការពារព្រៃឈើ។ នាពេលថ្មីៗនេះ ពួកគាត់បានទទួលពានរង្វាន់ពី the Global Landscape Forum 2020 Landscape Heroes Award ដែលជាការអបអរ ចំពោះអ្នកដែលបានចាត់វិធានការ ក្នុងការការពារជីវចម្រុះរបស់ភពផែនដី ភាគច្រើនគឺ ចំពោះបុគ្គលដែលបានប្រឈមជាមួយនឹងហានីភ័យធំៗ។ បណ្តាញគឺត្រូវបានជ្រើសរើសដោយគណកម្មការជំនាញមួយក្រុម ក្នុងចំណោមបេក្ខភាពជាង៨០ មកពីជុំវិញពិភពលោក គឺបានទទួលស្គាល់នូវការបន្តឧទ្ទិសដល់ការអភិរក្សរបស់បណ្តាញសហគមន៍ព្រៃឡង់។

គោលបំណងរបស់បណ្តាញសហគមន៍ព្រៃឡង់ គឺបម្រើដល់ការធ្វើឲ្យសហគមន៍មានសាមគ្គីភាពលើកិច្ចការសហគ្រប់គ្រងការពារព្រៃឈើ។ បណ្តាញសហគមន៍ព្រៃឡង់ពុំមានចេតនាបង្កើតជាស្ថាប័នផ្លូវការណាមួយដើម្បីធ្វើកិច្ចការតស៊ូមតិឡើយ គឺប្រាថ្នាត្រឹមតែជាបណ្តាញមិនផ្លូវការដដែលប៉ុណ្ណោះ។

ក្នុងគ្រាដែលមានការកើនឡើងនូវការកាប់បំផ្លាញព្រៃឈើក្នុងតំបន់ព្រៃឡង់ នាប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ គឺមានការចងក្រងនូវហេតុការណ៍នានាទុកបានយ៉ាងល្អ សូមធ្វើការដឹងគុណនូវការល្បាតរបស់សហគមន៍។ ការប្រឈមក្នុងឆ្នាំ២០២០ បានធ្វើការប្រមូលទិន្នន័យពីមូលដ្ឋានយ៉ាងលំបាក ក្នុងពេលតែមួយស្ទើរតែមិនអាចធ្វើបាន។ ការវិតបន្តឹងរួមជាមួយការរីករាលដាលនូវមេរោគកូវិដ១៩ បន្ទាប់មកក្រសួងបរិស្ថាន បានដាក់បម្រាមដល់បណ្តាញសហគមន៍ព្រៃឡង់មិនឲ្យចូលល្បាតក្នុងដែនការពារជម្រកសត្វព្រៃ ជាលទ្ធផលគឺមានការកើនឡើងនូវសកម្មភាពកាប់ឈើយ៉ាងខ្លាំងក្លាក្នុងឆ្នាំ២០២០ ។

នៅពេលដែលការល្បាតរបស់បណ្តាញសហគមន៍ព្រៃឡង់ ត្រូវបានគេហាមឃាត់ មិនឲ្យចូលទៅក្នុងព្រៃ ការប្រើប្រាស់រូបភាពផ្កាយរណប និងការប្រើប្រាស់ប្រពន្ធ័ព័ត៌មានភូមិសាស្រ្ត (GPS) គឺមានសារៈសំខាន់ណាស់ក្នុងការចងក្រងឯកសារ នៃការកើនឡើងការកាប់បំផ្លាញ និងរិចរិលព្រៃឈើនៅក្នុងតំបន់ព្រៃឡង់។

ជាចុងក្រោយ បណ្តាញសហគមន៍ព្រៃឡង់ បានទទួលការបញ្ជាក់ពី ប្រពន្ធ័ផ្សព្វផ្សាយ ថា មានបណ្តាញខ្សែបញ្ជូនអគ្គីសនី ៥០០គីឡូវ៉ាត់ ដែលមានចម្ងាយប្រវែង ២០០គីឡូម៉ែត្រ ដែលគ្រោងនឹងតភ្ជាប់ពីភ្នំពេញទៅព្រំដែនកម្ពុជា-ឡាវ។ ផ្លូវដែលត្រូវបានស្នើសម្រាប់ខ្សែបញ្ជូនអគ្គីសនី ដែលត្រូវអូសកាត់ព្រៃការពារដែនជម្រកសត្វព្រៃព្រៃឡង់ (រូបភាព២)។ វានឹងនាំមកនូវការបាត់បង់ព្រៃឈើ ធនធានធម្មជាតិ




**រូបភាពទី២:** ជាផ្ទៃតែដែលមានគម្រោងសាងសង់បណ្តាញភ្លើង។ ចំណុចពណ៌ទឹកក្រូចជាចំៗ កំណត់ជាតំបន់កាប់បំផ្លាញព្រៃឈើ នៅក្នុងឆ្នាំ២០១៩ និង២០២០។ SQUARED AREAS DENOTE THE KOREA-BACKED TUMRING REDD+ AND JAPANESE CONGLOMERATE MITSUI REDD+ PROJECTS (DANIELLE KEETON-OLSEN/VOD) [6]

[2] របាយការណ៍បច្ចេកទេសស្តីពីការផ្លាស់ប្តូរគម្របព្រៃឈើនៅក្នុងតំបន់ការពារព្រៃឡង់ ក្នុងប្រទេសកម្ពុជាដោយ JSC និង CYN

[3] ព័ត៌មានបន្ថែមអំពីដីសម្បទានសេដ្ឋកិច្ចជុំវិញតំបន់ព្រៃឡង់ សូមអាន Inside and outside the maps: mutual accommodation and forest destruction in Cambodia, Canadian Journal of Development Studies / Revue canadienne d'études du développement, 38:3, 360-377, DOI: 10.1080/02255189.2017.1309313

[4] Hansen, M.C., Potapov, P.V., Moore, R., Hancher, M., Turubanova, S.A., Tyukavina, A., Thau, D., Stehman, S.V., Goetz, S.J., Loveland, T.R., Kommareddy, A., Egorov, A., Chini, L., Justice, C.O., and Townshend, J.R.G., 2013, High-Resolution Global Maps of 21st Century Forest Cover Change: Science, v. 342, no. 6160, p. 850-853, at

http://www.sciencemag.org/content/342/6160/850.abstract.

[5] ការប៉ាន់ស្មានផ្អែកទៅលើសហាទីតាំងខាងលើ-ជីវិតលើដី ដង់ស៊ីតេឈើជីវម៉ាសក្នុងឆ្នាំ២០០០ from Baccini et al. 2015 ជាមួយនឹងការបាត់បង់ព្រៃឈើប្រចាំឆ្នាំទិន្នន័យ២០០១ ដល់២០១៩ based on the method of Hansen et al.(២០១៣) ទាំងការប៉ាន់ស្មានលើ ៣០ ម៉ែត្រនៃដំណោះស្រាយទៅលើទំនាស់តិចតួច។ ការបំភាយរួមជាមួយបរិមាណកាបោនផ្សេងៗ ដូចជាជីវម៉ាស់ក្រោមដី និងកាបោនក្នុងដី គឺមិននៅក្នុងការប៉ាន់ស្មានរបស់ប្រទេសនៅពេលនេះទេ។

[6] មើលប្រអប់អត្ថបទទី១

និងការបម្លាស់ទីរបស់សត្វព្រៃ។ មានតំរូវការជាបន្ទាន់សម្រាប់ការវាយតំលៃផលប៉ះពាល់បរិស្ថាន (EIA) និងការពិគ្រោះយោបល់ជាសាធារណៈ ជាបន្តបន្ទាប់ជាមួយសហគមន៍ដែលរស់នៅ តំបន់ជិតដែនជម្រកសត្វព្រៃព្រៃឡង់ នៅមុនពេលចាប់ផ្តើមការសាងសង់។

ផ្នែកខាងក្រោមនេះ គូសបញ្ជាក់ពីការបាត់បង់ព្រៃឈើ ដែលត្រូវបានវិភាគដោយការបញ្ចូលទិន្នន័យ ពីឧបករណ៍តាមដានព្រៃឈើ ដែលអាចរំខានដល់ព្រៃឈើ និងសំណុំទិន្នន័យគម្របព្រៃឈើសកល(FCDM)។ លទ្ធផល នៃការល្បាតរបស់បណ្តាញសហគមន៍ព្រៃឡង់ ត្រូវបានបង្ហាញ បន្ទាប់មកមានការពិភាក្សា និងអនុសាសន៍ ដែលដាក់ចេញនូវជំហានបន្ទាប់សំខាន់ៗ ដើម្បីលើកកម្ពស់ការការពារដែនជម្រកសត្វព្រៃព្រៃឡង់។

[7] https://vodenglish.news/power-line-to-cut-through-prey-lang-troubling-conservation-partners/ https://phnompenhpost.com/business/govt-approves-over-830m-worth-electricity-projects
[8] Keeton-Olsen and Sirivadh, 2020 https://vodenglish.news/new-trails-satellite-images-point-to-more-logging-inside-prey-lang/
[9] Khorn Savi, 2020 https://www.phnompenhpost.com/national/forest-watch-dog-warned-against-satellite-imagery
[10] Personal communication, 2020
[11] https://www.tetratech.com/en/projects/usaid-greening-prey-lang-cambodia

## ប្រអប់អត្ថបទទី១- ការប្រឈមនឹងការរឹតបន្តឹងជាច្រើន របស់បណ្តាញសហគមន៍ព្រៃឡង់ ក្នុងឆ្នាំ២០២០

បណ្តាញសហគមន៍ព្រៃឡង់ កំពុងត្រូវបានហាមឃាត់ មិនឲ្យចូលទៅក្នុងការពារដែនជម្រកសត្វព្រៃព្រៃឡង់ ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០២០ ដែលជាការរាំងដ៏ខ្លាំងក្លាមួយទៅលើការឃ្លាំមើល សកម្មភាពកាប់ឈើខុសច្បាប់។ នៅក្នុងខែកុម្ភៈ ក្រុមល្បាតត្រូវបានរារាំង មិនឲ្យចូលព្រៃក្រោមហេតុផល កូវីដ១៩ មករិតបន្តឹងលើសកម្មភាពរបស់ពួកគេ។ បន្ទាប់ពីខែនោះមក មន្ត្រីឧទ្យានុរក្សរបស់ក្រសួងបរិស្ថានដែលពាក់ម៉ាស់ បានរារាំងសមាជិកសហគមន៍ សកម្មជន និងព្រះសង្ឃរាប់រយនាក់មិនឲ្យចូលទៅប្រារព្ធពិធីបុណ្យរំលឹកគុណព្រៃឈើប្រចាំឆ្នាំ៨។

នៅក្នុងខែមីនា សកម្មជនម្ចាស់ពានរង្វាន់វិរៈជនបរិស្ថាន លោក អ៊ូច ឡេង សមាជិកបណ្តាញសហគមន៍ព្រៃឡង់ពីរនាក់ (លោក ខេម សុឃី និង លោក ស្រី ថី) និងសកម្មជន លោក ម៉ែន ម៉ាត់ ត្រូវបានចាប់ខ្លួននិងបញ្ជូនទៅឲ្យអាជ្ញាធរប៉ូលីស ដោយកងសន្តិសុខក្រុមហ៊ុនស៊ីងបាយអូធិក។ អ្នកទាំងបួនរូប ត្រូវបានដោះលែងវិញបន្ទាប់ពីឃុំខ្លួនអស់ជាច្រើនថ្ងៃ ប៉ុន្តែត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការសើបអង្កេត និងហាមឃាត់មិនឲ្យចូលក្នុងតំបន់ព្រៃឡង់។ លើសពីនេះទៅទៀត បណ្តាញសហគមន៍ព្រៃឡង់ ត្រូវបានគម្រាមចាប់ខ្លួន ប្រសិនបើការឃ្លាំមើលព្រៃឈើតាមផ្កាយរណបនៅតែបន្ត៩។ ជាចុងក្រោយ សមាជិកបណ្តាញសហគមន៍ព្រៃឡង់ម្នាក់ទៀតត្រូវបានគេឃាឃី និងគម្រាមរកចាប់ខ្លួនស្តីពីការចោទប្រកាន់ និងបានរត់គេចខ្លួនចេញពីផ្ទះហើយសព្វថ្ងៃនេះកំពុងរស់នៅនិរទេសខ្លួន១០។ ស្ទើរតែពេញមួយឆ្នាំ ត្រូវបានមើលឃើញថា បានបន្តរិតបន្តឹងទៅលើសមាជិកបណ្តាញសហគមន៍ព្រៃឡង់មិនឲ្យចូលទៅក្នុងព្រៃ។



## ប្រអប់អត្ថបទទី២- USAID ព្រៃឡង់បៃតង ការផាត់ចេញបណ្តាញសហគមន៍ព្រៃឡង់៖ ជាវិធីសាស្រ្តមួយបង្ករទំនាស់?

ក្នុងឆ្នាំ២០២០ ក្រសួងបរិស្ថានបានបង្កើនការរិតបន្តឹង និងចោទប្រកាន់ពីបទឧក្រិដ្ឋលើបណ្តាញសហគមន៍ព្រៃឡង់។ ការហាមឃាត់ការល្បាតរបស់បណ្តាញសហគមន៍ព្រៃឡង់បានកើតឡើងតំណាលគ្នា ជាមួយនឹងការចាប់ផ្តើមអនុវត្តគម្រោងព្រៃឡង់បៃតងរបស់USAID ក្នុងគោលបំណងដើម្បី “លើកកំពស់ការអភិរក្សភាពធន និងការបំភាយទាបដើម្បីការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព”១១។ នៅមុនពេលការចាប់ផ្តើមនៃគម្រោងព្រៃឡង់បៃតង ក្រសួងបរិស្ថានធ្លាប់បានអញ្ជើញបណ្តាញសហគមន៍ព្រៃឡង់ចូលរួមជាញឹកញាប់ក្នុងសិក្ខាសាលា និងការងាររបស់បណ្តាញ ត្រូវបានគេមើលឃើញថា ជាដៃគូពាក់ពន្ធ័ដ៏សំខាន់ ក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងព្រៃឡង់។ តាមរយៈជំនួយជាច្រើនលានដុល្លាទៅឲ្យក្រសួងបរិស្ថាន និងការផាត់ចេញបណ្តាញសហគមន៍ព្រៃឡង់ ពីសកម្មភាពល្បាតព្រៃ USAID និងដៃគូអនុវត្ត Tetra Tech គឺកំពុងគាំទ្រសកម្មភាពតែមួយគត់គឺ “កិច្ចការពារព្រៃឈើ” ស្ថិតក្រោមក្រសួងបរិស្ថាន។ ដោយបានអនុញ្ញាតិយ៉ាងស្ងៀមស្ងាត់ ឲ្យមានការបំភិតបំភ័យនិងការបំបែកភាពស្របច្បាប់របស់បណ្តាញសហគមន៍ព្រៃឡង់។ USAID និង Tetra Tech គឺកំពុងតែបំផ្លាញកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមនៅក្នុងស្រុក និងក្រុមជនជាតិដើមភាគតិចនៅមូលដ្ឋានដែលមានស្រាប់ ក្នុងរៀបចំការឃ្លាំមើលព្រៃឈើដ៏សំខាន់មួយនេះ។

FIGURE 3 Luxury timber tree recorded on 15/10/2019 at Preah Vihear province

# រូបភាពផ្កាយរណប រួមបញ្ចូលជាមួយនឹង រូបភាពអ្នកល្បាតនៅ មូលដ្ឋាន៖

# ជាឧបករណ៍គ្រួតពិនិត្យដ៏មានអនុភាព




រូបភាពទី៣:

ការមើលឃើញការរំខានដល់ព្រៃឈើក្នុងកំឡុងពេល មិថុនា ២០១៩-មិថុនា ២០២០ ដែលបានដាក់បញ្ចូលទៅក្នុង គម្របព្រៃឈើសកល (GFC) ឆ្នាំ២០១៩ (ការប្រើប្រាស់ គម្របព្រៃឈើអប្បបរមា ៣០ភាគរយ)

ការរំខានដល់ព្រៃឈើត្រូវបានការពារ ដោយការប្រើប្រាស់ឧបករណ៍ FCDM បានអភិវឌ្ឍដោយ មជ្ឈមណ្ឌលសិក្សារួមគ្នា (JRC) នៃគណកម្មការសហគមន៍អឺរ៉ុប (EC)១២។ FCDM ជាឧបករណ៍ រួមបញ្ចូលគ្នានូវវិធីសាស្រ្ត១៣ (ផ្អែកលើអុបទិក) Delta-NBER ជាមួយវិធីសាស្រ្ត១៤ (ផ្អែកលើរ៉ាដា) Delta-SPE ដោយប្រើរូបភាពផ្កាយរណបពី Sentinel-១, Sentinel-២ ក៏ដូចជា Landsat ៥, ៧ និង៨។ ជាលទ្ធផល ផែនទីនៃការរំខានដល់ព្រៃឈើ គឺផ្អែកទៅលើទិន្នន័យរ៉ាដាតែមួយប៉ុណ្ណោះ ហើយត្រូវបានគេចាត់ទុកថាអភិរក្ស មានន័យថាវាបង្ហាញតិចតួច ជាងការរកឃើញច្រើន (រូបភាពទី៣-៥) ។ ការរំខានព្រៃឈើដែលត្រូវបានរកឃើញក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៩ ដល់ខែមិថុនា ឆ្នាំ២០២០ បានប៉ះពាល់ដល់ផ្ទៃដីយ៉ាងហោចណាស់ ១០,៧៣៣ហិតា បើប្រៀបធៀបទៅនឹងឆ្នាំមុន១៥។

ផែនទីក្នុងរូបភាពទី៣-៥ គឺបានបង្ហាញជាមួយនឹងការកត់ត្រារបស់បណ្តាញសហគមន៍ព្រៃឡង់ អំពីការកាប់ឈើ និងបម្រែបម្រួលអាកាសធាតុ ទាក់ទងទៅនឹងព្រឹត្តិការណ៍ក្នុងតំបន់ការពារដែនជម្រកសត្វព្រៃព្រៃឡង់ និងតំបន់ជុំវិញនៅក្នុងកំឡុងខែមិថុនា ឆ្នាំ២០១៩ ដល់មិថុនា ឆ្នាំ២០២០។ បណ្តាញសហគមន៍ព្រៃឡង់បានកត់ត្រាឯកសារចំនួន ១៥២ហេតុការណ៍ ជាមួយនិងនីយាមកាGPS ភាគច្រើនគឺសកម្មភាពកាប់ឈើខុសច្បាប់  ហើយក្រៅពីនោះ គឺជាការសង្កេតទៅលើបម្រែបម្រួលអាកាសធាតុ (ដូចជាកម្រិតទឹកស្ទឹង និងបឹងមានការធ្លាក់ចុះ) និងមានករណីចំនួនពីរទៀត គឺជាភាពអវិជ្ជមាន នៃការធ្វើអន្តរកម្មជាមួយអាជ្ញាធរ។



រូបភាពទី៥:



រូបភាពទី៦:

Enlarged Northwest (Fig 5) and Southeast (Fig 6) parts of Prey Lang Wildlife Sanctuary

[12] Langner A, Desclée B, Carboni S, Vancutsem C, Stibig H-J, Achard F, Theilade I, Forest encroachments and logging activities within the Prey Lang Wildlife Sanctuary, Cambodia - Assessment of a new monitoring approach: radar-based Forest Canopy Disturbance Monitoring (FCDM-radar), European Commission, Ispra, 2020, JRC122187.

[13] Langner, A.; Miettinen, J.; Kukkonen, M.; Vancutsem, C.; Simonetti, D.; Vieilledent, G.; Verhegghen, A.; Gallego, J.; Stibig, H.-J. Towards Operational Monitoring of Forest Canopy Disturbance in Evergreen Rain Forests: A Test Case in Continental Southeast Asia. Remote Sens. 2018, 10, 544

[14] Langner, A., et al. Monitoring large- and small-scale changes in vegetation cover in the dry and humid domain using multi-temporal Sentinel-1 data, in preparation

[15] FCDM datasets were post-processed using Hansen dataset forest masks. However, the masks refer to the situation at the end of a calendar year while the FCDM datasets were derived from June one year to June the following year. This means that the resulting areas of forest disturbance provided above are conservative and the actual numbers are likely to be much higher.




**រូបភាពទី៦៖** ការកត់តាសកម្មភាពកាប់ឈើខុសច្បាប់ ដោយបណ្តាញសហគមន៍ព្រៃឡង់ ខែមិថុនា ឆ្នាំ២០១៩ ដល់ខែមិថុនា ឆ្នាំ២០២០

ការកត់ត្រា នៃការកាប់ឈើ ខុសច្បាប់

**រូបភាពទី៧៖** ការកត់ត្រាពីធនធានធម្មជាតិ ចាប់ពីខែមិថុនា ឆ្នាំ២០១៩ ដល់ខែមិថុនា ឆ្នាំ២០២០២០

ការកត់ត្រាពីជីវចម្រុះ និងទីតាំងជំនឿ








# ទិន្នន័យឃ្លាំមើល ប្រមូលដោយ បណ្តាញសហគមន៍ព្រៃឡង់

បណ្តាញសហគមន៍ព្រៃឡង់ បានកត់ត្រាចំនួន ៦០២ករណី ចន្លោះពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០១៦។ ការធ្វើសុពលភាព នៃការបញ្ចូលទិន្នន័យនេះ គឺមានពីរលក្ខណ្ឌ៖ សកម្មភាពខុសច្បាប់ និងធនធានធម្មជាតិ។ ការបញ្ចូលទិន្នន័យសរុបចំនួន ២៩៦ទិន្នន័យ ត្រូវបានកត់ត្រាលើសកម្មភាពខុសច្បាប់ក្នុងតំបន់ព្រៃការពារដែនជម្រកសត្វព្រៃព្រៃឡង់ ៤៩% និងការធ្វើសេចក្តីរាយការណ៍ចំនួន ២៨០ទិន្នន័យ លើធនធានមានតម្លៃ ៤៦%។ នៅសល់ចំនួន ៥% គឺជាធាតុចូលរវាងការអង្កេតការប្រែប្រួលអាកាសធាតុ និងការធ្វើអន្តរសកម្មជាមួយអាជ្ញាធរ (មិនមានបង្ហាញក្នុងគំនូស)។
ស្ទើរតែ ៩៩% សំដៅទៅលើសកម្មភាពកាប់ឈើខុសច្បាប់ (មិនមានបង្ហាញក្នុងគំនូស)។ ការបញ្ចូលទិន្នន័យភាគច្រើនសំដៅលើការកាប់ឈើមានតម្លៃ (បង្ហាញដង្គត់ ៤៥%) និងគំនរឈើទុកចោលនៅតំបន់មួយ ២៩%។ ការបញ្ចូលទិន្នន័យសំដៅលើការកាប់រានដីព្រៃ ១៩% និងការដឹកជញ្ជូនឈើសរុប ៧%។ ការបញ្ចូលទិន្នន័យសកម្មភាពកាប់ឈើខុសច្បាប់ក្នុងខែមិថុនា ឆ្នាំ២០១៩ រហូតខែមិថុនា ឆ្នាំ២០២០ គឺបង្ហាញនៅក្នុងរូបភាពទី៦។ សមាជិករបស់បណ្តាញសហគមន៍ព្រៃឡង់ថ្លែងថា៖ “យើងចង់អភិរក្សព្រៃឡង់សម្រាប់មនុស្សជំនាន់ក្រោយ”។ ភាពស្រស់ស្អាតរបស់ព្រៃឡង់ ត្រូវបានចងក្រងជាឯកសារ យ៉ាងរស់រវើក ដោយទិន្នន័យរបស់ បណ្តាញសហគមន៍ព្រៃឡង់ ស្តីពីធនធានធម្មជាតិ និងទីតាំងជំនឿ។ ដើមឈើ ត្រូវបានរាយការណ៍រហូតដល់ ៨១% ជាប្រភេទឈើប្រណីត អនុផលព្រៃឈើ ១០% សត្វព្រៃ ៨% និងតំបន់ជំនឿ ១% (ក្នុងរូបភាព៧)។

16 ការកត់ត្រាធ្វើឡើងដោយសមាជិកបណ្តាញសហគមន៍ព្រៃឡង់ គឺមិនបានផ្តល់តាមពេលវេលាឡើយ

**FIGURE 9**

**Cleared area reported in Kratie province on 24/11/2019**



តារាងទី១: ការសង្ខេបអំពីទិន្នន័យការឃ្លាំមើលព្រៃឈើ

# សេចក្ដីសង្ខេប

| | ខែមិថុនា ឆ្នាំ២០១៨-២០១៩ | ខែមិថុនា ឆ្នាំ២០១៩-២០២០ |
|---|---|---|
| សំណុំទិន្នន័យគម្របព្រៃឈើសកល* | 4.373 ហិកតា | 7.573 ហិកតា |
| ការបំភាយឧស្ម័នកាបូនិក ពីការបាត់បង់ជីវម៉ាស* | 2.03 MT | 3.52 MT |
| ការរកឃើញដោយ FCDM | 10.062 HA | 10.233 ហិកតា |
| ទិន្នន័យដាក់បញ្ចូលសកម្មភាពខុសច្បាប់ របស់ការល្បាតបណ្ដាញសហគមន៍ព្រៃឡង់ | 1080 | 296** |

*រយៈពេលពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩
**បណ្ដាញសហគមន៍ព្រៃឡង់ត្រូវបានហាមឃាត់មិនឲ្យចូលព្រៃ តាំងពីខែកុម្ភៈ ឆ្នាំ២០២០

ទិន្នន័យពីផ្កាយរណប បានបង្ហាញនូវការកើនឡើង នៃការបាត់បង់ព្រៃឈើ បើប្រៀបធៀបទៅនឹងឆ្នាំមុន។ ការបាត់បង់យ៉ាងរហ័សនូវជីវម៉ាស មានការកើនឡើង នៃកាបំភាយ នៃឧស្ម័នកាបូនិក (មើលនៅតារាងទី១)។ ការរំខានដល់គម្របព្រៃឈើ ត្រូវបានរកឃើញដោយឧបករណ៍ FCDM គឺបានកើនឡើងទៅលើរូបភាពដូចគ្នាទៅនឹងរយៈពេលដែលសន្ទត់ ទៅលើព្រៃឈើជាច្រើន ដូចជា ទំហំទិន្នន័យគម្របព្រៃឈើដែលបានរាប់បញ្ចូល រួចហើយទៅលើការអភិវឌ្ឍធុនធ្ងន់ដែលប៉ះពាល់ដល់ការកាប់បំផ្លាញព្រៃឈើ។
ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០២០ បណ្ដាញសហគមន៍ព្រៃឡង់ និងអ្នកការពារព្រៃឈើដទៃទៀត ត្រូវការហាមឃាត់មិនឲ្យចូលទៅក្នុងព្រៃដើម្បីឃ្លាំមើលការកាប់បំផ្លាញព្រៃឈើខុសច្បាប់។ នៅខណៈពេលដែលសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចត្រូវបានគេផាតចេញពីការការពារព្រៃឈើ។ មានសាក្សីជាច្រើនបានរៀបរាប់នូវសកម្មភាពអ្នកកាប់ឈើកំពុងតែចូលកាប់ និងការដឹកជញ្ជូនឈើដោយរថយន្តធំៗ ចេញពីក្នុងព្រៃ។ រួមជាមួយនឹងទិន្នន័យពីផ្កាយរណប បានបង្ហាញពីការរិចរិលព្រៃឈើយ៉ាងធំធេង និងហេតុការណ៍នៃការកាប់បំផ្លាញព្រៃឈើ។ របាយការណ៍ទាំងនេះ បានបង្ហាញថា៖

## រាជរដ្ឋាភិបាលហាមឃាត់មកលើការល្បាតព្រៃ បាននាំឱ្យមានការកើនឡើងនៃការបាត់បង់ព្រៃឈើ

ទិន្នន័យផ្កាយរណប ស្ដីពីការបាត់បង់ព្រៃឈើ បានបង្ហាញភាពទាក់ទងគ្នារវាង ការហាមឃាត់ទៅលើការល្បាតព្រៃរបស់បណ្ដាញសហគមន៍ព្រៃឡង់ ជាមួយនឹងការកើនឡើងនូវសកម្មភាពកាប់ឈើខុសច្បាប់ដោយក្រុមហ៊ុនកាប់ឈើ ដែលកំពុងប្រតិបត្តិការនៅតំបន់ជុំវិញព្រៃឡង់។

ឆ្នាំនេះ គឺបានបង្ហាញថា វត្តមាននៃការល្បាតរបស់បណ្ដាញសហគមន៍ព្រៃឡង់ បានធ្វើឲ្យអ្នកកាប់ឈើខ្លបខ្លាច។ ការខកខានការល្បាតព្រៃរបស់សហគមន៍ បានផ្ដល់នូវជម្រើសល្អឥតខ្ចោះ សម្រាប់សន្ទុះ និងការមិនអាចគ្រប់គ្រងបាននូវកាប់បំផ្លាញព្រៃឈើ និងការរិចរិលព្រៃឈើ។ លើសពីនេះទៅទៀត ភាពជឿទុកចិត្តបាន និងតម្លាភាពនៃពត៌មាននៅកំរិតមូលដ្ឋាន គឺមានភាពខ្វះចន្លោះចំពោះ ស្ថានភាពនៃបច្ចុប្បន្នភាពជីវចម្រុះ  សកម្មភាពកាប់បំផ្លាញធម្មជាតិខុសច្បាប់ និងការឆ្លើយតបរបស់ក្រុមហ៊ុន។

ការបណ្ដោយឲ្យមានការបំផ្លាញព្រៃឈើនៅតែបន្តកើតមាន គឺប៉ះពាល់ដល់ការការពារ បីតិកភណ្ឌធម្មជាតិរបស់កម្ពុជា និងសហគមន៍ដែលពឹងផ្អែកលើបេតិកភណ្ឌនេះ សម្រាប់ការរស់នៅរបស់ពួកគេ។ វាក៏រាំងដល់សមត្ថភាពរបស់ជាតិ ក្នុងការឆ្លើយតបទៅនឹងប្រសិទ្ធិភាពនៃបម្រែបម្រួលអាកាសធាតុផងដែរ។ កិច្ចការពារប្រព័ន្ធអេកូឡូស៊ីព្រៃឈើធម្មជាតិនៃព្រៃឡង់គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសជាតិ ដើម្បីកាត់បន្ថយការបំភាយឧស្ម័នកាបូនិច។

# អនុសាសន៍

FIGURE 11

Cleared area with planks left on site, recorded in Kratie province 29/08/2019



## យើងខ្ញុំជាបណ្តាញសហគមន៍ព្រៃឡង់ សូមផ្តល់នូវអនុសាសន៍មួយចំនួន៖

### អនុសាសន៍ជាក់លាក់៖

1. **យើងខ្ញុំសូមជំរុញដល់រាជរដ្ឋាភិបាល ជាពិសេសក្រសួងបរិស្ថាន ត្រូវតែទទួលស្គាល់តួនាទីដ៏សំខាន់របស់បណ្តាញសហគមន៍ព្រៃឡង់ ដែលដើរតួនាទីក្នុងកិច្ចការពារព្រៃឡង់ និងដកបម្រាមដែលហាមឃាត់លើបណ្តាញសហគមន៍ព្រៃឡង់ និងអ្នកការពារព្រៃឈើផ្សេងទៀតក្នុងការល្បាតព្រៃ។**
2. **យើងខ្ញុំសូមជំរុញដល់រាជរដ្ឋាភិបាលកម្ពុជា បញ្ឈប់នូវការប្រើប្រាស់ប្រព័ន្ធតុលាការ ដើម្បីចោទប្រកាន់មកលើសមាជិកបណ្តាញសហគមន៍ព្រៃឡង់ និងសកម្មជនបរិស្ថានដ៏ទៃទៀត។ សមាជិកសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច** គឺជាសហគមន៍ពាក់ពន្ធ័ស្របច្បាប់ ក្នុងការការពារព្រៃឈើ និងទាញយកចំណែកដ៏ធំសម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគេ ដោយផ្ទាល់ ឬប្រយោលពីព្រៃឈើ។ ដូចជា កិច្ចការពារព្រៃឈើ គឺជាកន្លឹះអាទិភាពរបស់បណ្តាញព្រៃឡង់។
3. **យើងសូមជម្រុញឲ្យក្រសួងបរិស្ថាន ធ្វើការសិក្សាស្រាវជ្រាវផលប៉ះពាល់បរិស្ថាន (EIA)** និងការពិគ្រោះយោបល់ជាសាធារណៈមុនពេលសាងសង់ខ្សែបញ្ជូនអគ្គីនី និងចែករំលែកលទ្ធផលដល់សាធារណៈជន។

### អនុសាសន៍ទូទៅ៖ [17]

1. **រាជរដ្ឋាភិបាលគួរទទួលស្គាល់នូវគុណតម្លៃ នៃប្រព័ន្ធព័ត៌មានវិទ្យាសាស្រ្តពលរដ្ឋ (Geographic Citizen Science) ដែលប្រើប្រាសក្នុងការឃ្លាំមើលបទល្មើសព្រៃឈើ។** អ្នកល្បាតព្រៃឈើនៅមូលដ្ឋាន បានប្រើប្រាស់ព័ត៌មាន និងបច្ចេកវិជ្ជាទំនាក់ទំនងដែលមានតម្លៃថោក និងមានប្រសិទ្ធិភាព ជាងការល្បាតព្រៃ របស់មន្រ្តីឧទ្យានុរក្ស របស់រាជរដ្ឋាភិបាល។ ប្រព័ន្ធព័ត៌មានវិទ្យាសាស្រ្តពលរដ្ឋ រាប់បញ្ចូល នូវសមាជិកសហគមន៍ ដែលអាចប្រើប្រាស់កម្មវិធីអេបព្រៃឡង់ ដោយមិនគិតពីអាយុ និងភេទ។

2. **ម្ចាស់ជំនួយគួរតែបង្កើនជំនួយដល់** ប្រព័ន្ធព័ត៌មានវិទ្យាសាស្រ្តពលរដ្ឋ។ កម្មវិធីអេបព្រៃឡង់ បានជួយសម្របសម្រួលដល់ការប្រើប្រាស់លទ្ធផល ក្នុងការតស៊ូមតិ តាមបណ្តាញទំនាក់ទំនងសង្គម និងដើម្បីធ្វើញត្តិដល់អាជ្ញាធររដ្ឋាភិបាលដែលពាក់ព័ន្ធ។

3. **ទីភ្នាក់ងារបរិស្ថាន គួរលើកទឹកចិត្តឱ្យប្រើប្រាស់ ប្រព័ន្ធព័ត៌មានវិទ្យាសាស្រ្តពលរដ្ឋ ក្នុងការឃ្លាំមើល បរិស្ថាន។** វាមានប្រសិទ្ធិភាពខ្ពស់ ជឿទុកចិត្តបាន ដឹកនាំសកម្មភាពនៅមូលដ្ឋាន និងពង្រឹងសិទ្ធិអំណាចដល់សង្គមស៊ីវិល។ វាមានគុណតម្លៃខ្ពស់សម្រាប់កិច្ចការការពារបរិស្ថាននៅទូទាំងតំបន់ត្រូពិក (ក្តៅហើយសើម) ការអភិរក្សសកល និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

[17] Bori, P. J., Argyriou, D., & Theilade, I. (2020). Geographic citizen science for forest monitoring and conservation. Policy Briefs (Copenhagen Centre for Development Research), 2020(2), 1-6.



Planks from Chkrom left on site, recorded 28/05/2020 in Kratie province

FIGURE 12

# សេចក្តីថ្លែងការណ៍ របស់បណ្តាញព្រៃឡង់



## ស្តីពី សកម្មភាពកាប់បំផ្លាញព្រៃឈើល្មើសច្បាប់ នៅក្នុងតំបន់ព្រៃឡង់នៅតែបន្តកើតមានយ៉ាងខ្លាំងក្លា

យើងខ្ញុំទាំងអស់គ្នាជាសមាជិកបណ្តាញសហគមន៍ព្រៃឡង់ទាំងបួនខេត្ត ក្រចេះ ស្ទឹងត្រែង ព្រះវិហារ និងកំពង់ធំ ដែលកំពុងធ្វើការងារស្ម័គ្រចិត្តការពារ ព្រៃការពារដែនជម្រកសត្វព្រៃ ព្រៃឡង់ អស់រយៈពេលជាង ២០ឆ្នាំមកហើយ បាននឹងកំពុងបន្តឃ្លាំមើល សកម្មភាពកាប់ឈើ ការដឹកជញ្ជូនឈើ និងការបរបាញ់សត្វព្រៃអានាធិបតេយ្យយ៉ាងយកចិត្តទុកដាក់ បើទោះជាបណ្តាញត្រូវបានហាមឃាត់មិនឱ្យចុះល្បាតក្នុងតំបន់ការពារព្រៃឡង់កាលពីខែកុម្ភៈដើមឆ្នាំ២០២០ ដោយក្រសួងបរិស្ថានក៏ដោយ។

នៅពេលដែលព្រៃឡង់ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការងារគ្រប់គ្រងរបស់ក្រសួងបរិស្ថាន យើងខ្ញុំសង្កេតឃើញថា បទល្មើសមានការកើនឡើងច្រើនជាង ការគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ ហើយអ្វីដែលគួរឱ្យកត់សម្គាល់ជាងនេះទៅទៀតនោះគឺ តាំងពីក្រសួងបរិស្ថានបានហាមឃាត់បណ្តាញសហគមន៍ព្រៃឡង់មិនឱ្យចុះល្បាត បទល្មើសមានសេរីភាពចេញចូលព្រៃកាប់ និងដឹកជញ្ជូនឈើបានយ៉ាងរលូន ដោយគ្រាន់តែបង់ប្រាក់ជូនមន្រ្តីតាមស្នាក់ការត្រួតពិនិត្យ ជាថ្នូនឹងការទទួលបានការអនុញ្ញាតិឱ្យប្រព្រឹត្តបទល្មើសក្នុងព្រៃឡង់។

ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០២០មក យើងខ្ញុំទាំងអស់គ្នា បានសង្កេតឃើញ សកម្មភាពល្មើសច្បាប់អនាធិបតេយ្យនៅជុំវិញតំបន់ព្រៃឡង់ កើតមានយ៉ាងខ្លាំងក្លាដូចជា៖

**១). ការកាប់បំផ្លាញដើមជំរច្បោះនិងដើមឈើធំៗនៅក្នុងតំបន់ព្រៃឡង់ ដោយជនអនាធិបតេយ្យ និងក្រុមហ៊ុន Think Biotech Co.,Ltd ក្រុមហ៊ុន Thy Nha Co., Ltd. Development and Investment និងក្រុមហ៊ុន PNT ។**
**២). ការអនុញ្ញាតឲ្យមានការដឹកជញ្ជូនឈើជាច្រើនគោយន្តក្នុងមួយថ្ងៃៗ និងឧបករណ៍សម្រួលដល់ការកាប់ឈើ ឆ្លងកាត់មុខស្នាក់ការយាមល្បាតរបស់មន្ត្រីឧទ្យានុរក្សនីមួយៗ។**
**៣). ការកាប់រានដីព្រៃនៅក្នុង និងព្រៃតំបន់ទ្រនាប់ព្រៃការពារដែនជម្រកសត្វព្រៃ ព្រៃឡង់ ដោយអ្នកមានអំណាច និងប្រជាពលរដ្ឋអ្នកចំណូលថ្មី។**
**៤). ការប្រើប្រាស់អាវុធកែច្នៃ និងការប្រើប្រាស់អន្ទាក់នៅជុំវិញតំបន់ព្រៃឡង់ ក្នុងគោលបំណងបរបាញ់និងទាក់សត្វព្រៃ។**

សកម្មភាពល្មើសច្បាប់អាណាធិបតេយ្យទាំងបួនធំៗខាងលើនេះ យើងខ្ញុំទាំងអស់គ្នាបានកត់សម្គាល់ឃើញថា គ្មានវិធានការណាមួយទប់ស្កាត់គួរឱ្យកត់សម្គាល់ឡើយ។ យើងខ្ញុំទាំងអស់គ្នា សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងបរិស្ថាន និងអាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់មេត្តា៖

**១. ស្នើសុំអោយរាជរដ្ឋាភិបាលតាមដានត្រួតពិនិត្យ និងដកចេញពីតួនាទីជាមន្ត្រីឧទ្យានរក្ស ចំពោះមន្ត្រីរូបណាដែលពាក់ព័ន្ធជាមួយបទល្មើស និងអសកម្មក្នុងការបំពេញតួនាទីរបស់ខ្លួន។**
**២. បញ្ឈប់ការអនុញ្ញាតឲ្យមានការដឹកជញ្ជូនឈើ ម៉ាស៊ីនរណាយន្ត និងសំភារៈផ្សេងទៀតសំរាប់បម្រើអោយការកាប់បំផ្លាញព្រៃឈើកាត់មុខប៉ុស្តិ៍យាមរបស់មន្ត្រីឧទ្យានុរក្សនីមួយៗ។**
**៣. ស្នើសុំឲ្យក្រសួងបរិស្ថាន រៀបចំផែនការយុទ្ធសាស្រ្តជាក់លាក់ ក្នុងការប្រយុទ្ធប្រឆាំងការកាប់បំផ្លាញព្រៃឈើ និងការកាប់រានដីព្រៃសំរាប់កសិកម្មថ្មីៗ កាំភ្លើងកែឆ្នៃ ការបរបាញ់ និងសំភារៈសំរាប់បំរើអោយការប្រព្រឹត្តិបទល្មើសផ្សេងទៀត។**
**៤. សូមឱ្យរាជរដ្ឋាភិបាល ចាត់វិធានការដកហូតម៉ាស៊ីនរណាយន្តទាំងអស់ ចេញពីភូមិឃុំស្រុក ខេត្ត និងទីតាំងធ្វើអាជីវកម្ម នៅជុំវិញព្រៃឡង់ទាំងបួនខេត្ត និងបញ្ឈប់ការនាំចូលបន្តទៀត។**
**៥. រាជរដ្ឋាភិបាលត្រូវតែអនុវត្តន៍បទបញ្ញត្ត នឹងច្បាប់នានាក្នុងកិច្ចការការពារព្រៃឈើ។**
**៦. អំពាវនាវ និងលើកទឹកចិត្តដល់ប្រជាជនកម្ពុជា និងសាកលលោក សូមចូលរួមយ៉ាងសកម្ម និងធ្វើការទាំងអស់គ្នាទោះដោយផ្ទាល់ ឬប្រយោលដើម្បីបុព្វហេតុការពារធនធានធម្មជាតិ។**
**៧. សូមអោយតួអង្គអន្តរជាតិសំខាន់ៗ ធ្វើការចាប់អារម្មណ៍វិភាជ៍ធនធានដល់កម្ពុជា និងបណ្តាប្រទេសដែលរងផលប៉ះពាល់ការកាប់បំផ្លាញព្រៃឈើ និងធនធានធម្មជាតិ។**

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតំណាងសហគមន៍តាមរយៈលេខទូរស័ព្ទដូចខាងក្រោម៖

លោក ឯក សុវណ្ណា ០៩៧ ៦៤៤ ៩៩៩៨ | លោក ស្វាយ សុង ០៧១ ៤៥១ ៩៤៦៥ | លោក ស្រី ថី ០៩៩ ៧២២ ១៨៧ | លោក ខេម សុឃី ០៨៥ ៤៧៣ ១៥៧ | លោក មិញ នី ០៩៦ ៣០០ ២៧៦២ | លោក ហឿន សុភាព ០១២ ៣៧៣ ៤៤១ | កញ្ញា ឈាង លី ០៩៦ ៦៦៨ ០៦៧៣ | លោក ខេង ខូ ០៧១ ៤៥១ ៩៤៦៣



# យើងរួមគ្នា ការពារព្រៃឡង់ ព្រៃឡង់ ជា ព្រៃរបស់យើង ទាំងអស់គ្នា!

PREY LANG
IT'S OUR FOREST TOO

https://preylang.net/

ព័ត៌មានមាននៅក្នុងឯកសារនេះ គឺជាកម្មសិទ្ធិរបស់បណ្ដាញសហគមន៍ព្រៃឡង់។ អ្នកទាំងអស់គ្នាត្រូវបានស្វាគមន៍ក្នុងការប្រើប្រាស់ បោះពុម្ព និងការចែកចាយឯកសារនេះជាប្រភពនៃឯកសារយោង។ សាកលវិទ្យាល័យកូប៉ិនហាហ្គិន បានស្នើឲ្យក្រសួងបរិស្ថាន ផ្ដល់អនុសាសលើរបាយការណ៍នេះ ប៉ុន្តែមិនទទួលបាននូវការឆ្លើយតបណាមួយឡើយ។

បណ្ដាញសហគមន៍ព្រៃឡង់ណា សូមថ្លែងអំណរគុណដល់ (មជ្ឈមណ្ឌលរួមគ្នាសិក្សាស្រាវជ្រាវ របស់គណកម្មការសហគមន៍អឺរ៉ុប) ដែលបានផ្ដល់នូវបច្ចេកទេសដើម្បីចែកចាយនូវទិន្នន័យ នៃការរីខានព្រៃឈើ ដោយប្រើប្រាស់ឧបករណ៍ FCDM អ្នកហាត់ការ នៃសាកលវិទ្យាល័យកូប៉ិនហាហ្គិន និងអ្នកទាំងអស់គ្នាដែលបានស្មគ្រចិត្តជ្រោមជ្រែង។ របាយការណ៍នេះ នឹងមិនអាចផលិតបានទេ ប្រសិនបើគ្មានពួកគេទាំងអស់គ្នានោះ។

កម្មវិធីអេបព្រៃឡង់ ត្រូវបានបង្កើតឡើងដោយ **Sapelli:** គឺជាគម្រោងកម្មវិធីបើកទូលាយមួយ ដែលសម្របសម្រួលការប្រមូទិន្នន័យតាមភាសាផ្សេងៗគ្នា ឬអ្នកដែលមិនចេះអក្សេ តាមរយៈ highly configurable icon-driven user interfaces. សម្រាប់ព័ត៌មានបន្ថែម http://www.sapelli.org/

រូបភាពទាំងអស់ជាកម្មសិទ្ធិបញ្ហារបស់បណ្ដាញព្រៃឡើង។ ផែនទីទាំងអស់ ត្រូវបានផលិតដោយ៖ QGIS.៣.៦.២ Noosa។

ការរចនាក្រាហ្វិច និងគំនូសព័ត៌មាន ត្រូវបានរចនាដោយ៖ Carolina Salassa (carolina.salassa@outlook.it)។ ឯកសារនេះ ត្រូវបានការពារក្រោមអាជ្ញាបណ្ណច្នៃប្រឌិត (CC BY-NC ៤.0)។ ទទួលបានការគាំទ្រផ្នែកថវិកាពី Alexander Soros Foundation។ បោះពុម្ពលើកទីមួយក្នុងខែមករា ឆ្នាំ២០២១។